**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

លេខ...០៧២......បទ.ស.ស.រ........

# សេចក្ដីសម្រេច
# ស្ដីពី
# ការកែសម្រួលសមាសភាពក្រុមបច្ចេកទេស របស់ក្រុមការងារនីតិកម្មនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ខែកញ្ញាឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៤ ចុះថ្ងៃទី២៤ខែកញ្ញាឆ្នាំ២០១៣ ស្ដីពីការតែងតាំងអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ខែមករាឆ្នាំ២០១៤ ស្ដីពីរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងសេចក្ដីសម្រេចលេខ ០៧១ បទ.សសរ ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១៤ ស្ដីពីការកែសម្រួលសមាសភាពក្រុមការងារនីតិកម្មរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងតាមការងារចាំបាច់របស់ក្រសួង។

## សម្រេច

**ប្រការ១ ..**

កែសម្រួលសមាសភាពក្រុមបច្ចេកទេសរបស់ក្រុមការងារនីតិកម្មនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ភាន ច័ន្ទមេត្តា** | រដ្ឋលេខាធិការ | ប្រធាន |
| ២- | ឯកឧត្តម **ខូង មករា** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣- | ឯកឧត្តម **គង់ សេង** | សមាជិកទី១នៃបញ្ញត្តិករទូរគមនាគមន៍កម្ពុជា | សមាជិក |
| ៤- | ឯកឧត្តម **តុល ញ៉ាក់** | អគ្គនាយកប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៥- | ឯកឧត្តម **ជា មានិត** | អគ្គនាយកបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន | សមាជិក |

| | | | |
|---|---|---|---|
| ៦- | លោក **ឡាយ ត្លុក** | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ៧- | លោក **អ៊ឹម ឌុស្លា** | ប្រធានអង្គភាពបញ្ញត្តិកម្ម និងវិវាទ នៃបញ្ញត្តិករទូរគមនាគមន៍កម្ពុជា | លេខាធិការ |

**ប្រការ២ .-**

ក្រុមបច្ចេកទេស ជាសេនាធិការឱ្យក្រុមការងារនីតិកម្មនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានភារកិច្ចដូចតទៅ ៖

- សហការជាមួយអង្គភាពជំនាញពាក់ព័ន្ធ ដើម្បីលើកគម្រោងជាអាទិភាព និងកសាងសេចក្ដីព្រាងច្បាប់ លិខិតបទដ្ឋានគតិយុត្តិ ស្របតាមគម្រោងរៀបចំលិខិតបទដ្ឋានគតិយុត្តិបច្ចុប្បន្នកម្មរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សម្រាប់ឆ្នាំ២០១៤-២០១៨។
- ចូលរួមប្រជុំពិភាក្សា រៀបចំសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានដែលត្រូវព្រាងឡើងក្នុងក្របខ័ណ្ឌជំនួយបច្ចេកទេស ឬសហប្រតិបត្តិការជាមួយបរទេសរបស់អង្គភាពដែលមានការពាក់ព័ន្ធ។
- ប្រជុំពិនិត្យ ពិភាក្សា និងកែសម្រួលជំហានដំបូងនូវរាល់សេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានមុនដាក់ឆ្លងអង្គប្រជុំក្រុមការងារនីតិកម្ម រួចទើបដាក់ជូនឯកឧត្តមរដ្ឋមន្ត្រីពិនិត្យសម្រេច។
- ធ្វើរបាយការណ៍សកម្មភាពការងារជូនឯកឧត្តមប្រធានក្រុមការងារនីតិកម្ម។

**ប្រការ៣ .-**

ឯកឧត្តមប្រធាន និងសមាជិកនៃក្រុមការងារបច្ចេកទេសរបស់ក្រុមការងារនីតិកម្ម ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ប្រធានអាចអញ្ជើញឯកឧត្តម និងមន្ត្រីជំនាញផ្សេងទៀតដែលមានការពាក់ព័ន្ធឱ្យចូលរួមក្នុងកិច្ចប្រជុំតាមករណីចាំបាច់។

**ប្រការ៤ .-**

សេចក្ដីសម្រេចលេខ ១៦២ បទ.សសរ ចុះថ្ងៃទី៣០ខែធ្នូឆ្នាំ២០១៣ ស្ដីពីការបង្កើតក្រុមការងារបច្ចេកទេសរបស់ក្រុមការងារនីតិកម្មនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវទុកជានិរាករណ៍។

**ប្រការ៥ .-**

ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ អគ្គនាយកដ្ឋានបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន អគ្គាធិការដ្ឋាន វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នាយកដ្ឋានសវនកម្មផ្ទៃក្នុង មន្ទីរ អង្គភាពទាំងអស់ក្រោមឱវាទក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងសាមីខ្លួន ត្រូវអនុវត្តតាមសេចក្ដីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ប្រាក់ សុខុន**

**កន្លែងទទួល ៖**

- ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួង
- ដូចប្រការ៥ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ